ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១១២/១៩ - ហ្គោ ជូន ត្រាវែល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្គោ ជូន ត្រាវែល ឃីវីស**
អាសយដ្ឋាន ៖ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០១២ ៤៣៨ ៩៩២ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោកស្រី Chang Shuling | ប្រធានក្រុមហ៊ុន |
| ២- លោកស្រី ស៊ីន ស៊ីនួន | អ្នកបកប្រែ |
| ៣- លោកស្រី អ៊ឹង ផារី | គណនេយ្យ |
| ៤- លោក ខៀវ ស៊ីសាវុន | ទីប្រឹក្សា |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោជូនត្រាវែលឃីវីស**
អាសយដ្ឋាន ៖ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០៩២ ៥១៩ ៨២៧ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ព្រិត សុអួត | មន្ត្រីច្បាប់មជ្ឈមណ្ឌលសាមគ្គីភាព (SC) |
| ២- លោក ប៉ាង ណារុំ | ប្រធានសហជីព (មូលដ្ឋាន) |
| ៣- លោក ជួន រ៉ាឌី | អនុប្រធានសហជីព (មូលដ្ឋាន) |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីសហជីពទាមទារបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិត ទាមទារឱ្យនិយោជក នៃក្រុមហ៊ុន ហ្គោ ថូន ត្រាវែល ស៊ីវីស អនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ដែលបានកំណត់ និងត្រូវធ្វើឡើងចំពោះមុខអធិការការងារ ជូនកម្មករនិយោជិតចំនួន ១៥(ដប់ប្រាំ)នាក់។ ភាគីនិយោជកបដិសេធការទាមទារបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ១៥(ដប់ប្រាំ) នាក់ បានទេ ដោយក្រុមហ៊ុន គឺនៅមានដំណើរការ នៅឡើយ ក្រុមហ៊ុនអាចបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតបានខ្លះ ទៅតាមដំណាក់កាល គឺមិនអាចកំណត់បានទេ និងតាមលទ្ធភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហើយអនុវត្តទូទាត់អត្ថប្រយោជន៍ផ្សេងៗ ទៅតាមច្បាប់ស្តីពីការងារ ដើម្បីបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតម្នាក់ៗ។ សហជីពបដិសេធការបញ្ចប់កិច្ចសន្យាការងារ តាមដំណាក់កាលៗ របស់និយោជក គឺមិនមានកាលបរិច្ឆេទច្បាស់លាស់ ដោយភាគីកម្មករនិយោជិត សុំឱ្យភាគីខាងនិយោជកបញ្ជាក់កាលបរិច្ឆេទឱ្យបានច្បាស់លាស់ ដោយចែកចេញជា ៣ដំណាក់កាល ក្នុងដំណាក់កាលនីមួយៗ គឺមានចំនួន ៥ នាក់ ក្នុងរយៈពេល ៣ ខែ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល ស៊ីវីស លេខ ១០៦ មកប ចុះថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោ ថូន ត្រាវែល ស៊ីវីស ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ២ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈខេត្តសៀមរាប បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា ហើយភាគីកម្មករនិយោជិតបានបញ្ចូលចំណុចវិវាទទាំងពីរ ជាចំណុចវិវាទតែមួយ។ ចំណុចមិនសះជានេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោ ថូន ត្រាវែល សឺវីស លេខ ១០៦ ម.ក.ប ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជកនិងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សា នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នា។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទ ១ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ជាកំណត់នៃការផ្តល់ភស្តុតាង និងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ជាថ្ងៃចុងក្រោយនៃការជំទាស់ភស្តុតាង។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន។**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស លេខ ៣៩០/១៩ កប/បវក ចុះថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

២- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស លេខ ០០៨ មកប ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

៣- លេខ ០០៨ មកប ចុះថ្ងៃសុក្រ ១១ រោច ខែភទ្របទ ឆ្នាំចរ សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស ជាអង្គការវិជ្ជាជីវៈមួយ បានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៤- លិខិតចាត់តាំងរបស់មជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីចាត់តាំងឈ្មោះ ព្រិត សុអួត មន្ត្រីច្បាប់ ចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០២/២០ ACILS ចុះថ្ងៃអង្គារ ៥ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០។

៥- លិខិតរបស់តំណាងសហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា គោរពជូន លោកប្រធានមជ្ឈមណ្ឌលសាមគ្គីភាព (SC) ស្តីពីស្នើសុំមេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិ ក្នុងការដោះស្រាយវិវាទការងារក្នុងប្រព័ន្ធតុលាការ និងលោក ព្រិត សុអួត សម្រាប់ការប្រឹក្សាយោបល់ ផ្នែកច្បាប់ក្រៅប្រព័ន្ធតុលាការ លេខ ០០៦៥/១៩ សជក ចុះថ្ងៃចន្ទ ១២ កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០។

៦- ពាក្យសុំជួយដោះស្រាយ និងផ្ទេរសិទ្ធិ ចុះថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោក ប៉ាង ណារុំ គោរពជូន លោក វ៉ន វ៉ាក់ន់ ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យដឹកជញ្ជូន ស្តីពីផ្ទេរសិទ្ធិជូនលោកប្រធានជួយចូលរួមធ្វើជាតំណាងអម និងសម្រេច ក្នុងការដោះស្រាយវិវាទការងាររួមជាមួយក្រុមហ៊ុន ហ្គោលថូន ត្រាវែល សឺវីស ទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ។

៧- លិខិតជូនដំណឹងរបស់ឈ្មោះ ប៉ាង ណារុំ ប្រធានសហជីពប្រជាធិបតេយ្យកម្មករនិយោជិត នៃក្រុមហ៊ុន ហ្គោលថូន ត្រាវែល សឺវីស គោរពជូន លោកស្រី ចាង ស៊ូលីង នាយិកានៃក្រុមហ៊ុន ហ្គោលថូន ត្រាវែល សឺវីស ស្តីពីឆ្លើយតបនឹងសំណើរបស់លោកស្រី បានស្នើសុំបញ្ចប់កិច្ចសន្យាការងាររួមជាមួយកម្មករនិយោជិតក្រៅផ្លូវច្បាប់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស លេខ ១០៦ មកប ចុះថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩។

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូនត្រាវែលសឺវីស ៣៩០/១៩ ក.ប/វ.ប/វ/ក ចុះថ្ងៃចន្ទ ១០ រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០០៦ កប/អក/វក/លក/អ. ចុះថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០០៧ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមករា ឆ្នាំ ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុន ហ្គោ ថូន ត្រាវែល សឺវីស គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកសេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរណ៍។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៣៣នាក់ (*យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោ ថូន ត្រាវែល សឺវីស*)។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៥នាក់ ចំពោះមុខអធិការការងារ និងអនុវត្តតាមនីតិវិធីដែលមានចែងក្នុងច្បាប់ស្តីពីការងារ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជករំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៤នាក់ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត។
- ភាគីទាំងពីរបានទទួលស្គាល់ថា៖
  - កម្មករនិយោជិតទាំង ១៤នាក់នេះ ធ្វើការដោយប្រើប្រាស់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ដែលបង្កើតឡើងដោយផ្ទាល់មាត់។
  - ក្រុមហ៊ុននៅមានដំណើរការជាធម្មតា គ្រាន់តែរយៈពេល ១ឆ្នាំ ចុងក្រោយនេះ និយោជកមិនសូវមានការងារឱ្យកម្មករនិយោជិតធ្វើ។
  - បើទោះជាការងារមានការធ្លាក់ចុះ និយោជកនៅតែបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ២ដងក្នុង ១ខែ ដោយទៀងទាត់។
  - ជាធម្មតានៅពេលដែលគ្មានការងារធ្វើ និយោជកអនុញ្ញាតឱ្យកម្មករនិយោជិតនៅផ្ទះ ហើយនៅពេលដែលមានការងារធ្វើ និយោជកហៅកម្មករនិយោជិតទៅក្រុមហ៊ុនដើម្បីជួយការងារជាក់ស្តែង។ ក្នុងអំឡុងពេលមិនសូវមានការងារធ្វើ និយោជកបានចាត់ចែងឱ្យកម្មករនិយោជិតខ្លះដឹកកូនរបស់និយោជកទៅនិងមកពីសាលារៀន ខ្លះយកអាហារឱ្យកូនរបស់និយោជកនៅសាលា និងខ្លះទៀតសម្អាតរថយន្តជាដើម។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - យោងតាមមាត្រា ៨៣ នៃច្បាប់ស្តីពីការងារ និយោជកមិនអាចជួលកម្មករនិយោជិតដោយមិនប្រគល់ការងារគ្រប់គ្រាន់សម្រាប់កម្មករនិយោជិតធ្វើនោះទេ។
  - យោងតាមមាត្រា ២ នៃច្បាប់ស្តីពីការងារ និយោជកគ្មានសិទ្ធិចាត់ចែងការងារឱ្យកម្មករនិយោជិតធ្វើដែលខុសពីជំនាញរបស់គាត់បានទេ។

THE ARBITRATION COUNCIL

- រថយន្តសម្រាប់ដឹកភ្ញៀវទេសចរណ៍ប្រមាណ ៩០ភាគរយ មិនអាចដំណើរការបាន ហេតុនេះ និយោជកពុំមានរថយន្តគ្រប់គ្រាន់សម្រាប់ឱ្យកម្មករនិយោជិតដឹកភ្ញៀវទេសចរណ៍ទេ។ សម្រាប់រថយន្តធុនតូច និយោជកទិញយកមកជួសជុលដើម្បីលក់បន្តតែប៉ុណ្ណោះ។
- កម្មករនិយោជិតផ្នែកជួសជុលរថយន្ត បានលាឈប់ពីការងារទាំងអស់។

- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ពីព្រោះ៖
  - និយោជកបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ២ដង ក្នុង១ខែ មិនដែលអាក់ខាននោះទេ។
  - និយោជកមិនបានប្រើកម្មករនិយោជិតខុសជំនាញទេ ពោលគឺនិយោជកបានចាត់ចែងឱ្យកម្មករនិយោជិតដឹកកូនរបស់និយោជកទៅសាលារៀន និងសម្អាតរថយន្តដែលជាកាតព្វកិច្ចរបស់កម្មករនិយោជិត។
  - ឡានសម្រាប់ដឹកភ្ញៀវទេសចរណ៍មានចំនួន ៤គ្រឿង ដែលដំណើរការធម្មតា ហើយសម្រាប់ឡានដែលមិនដំណើរការ និយោជកនឹងជួសជុលនៅពេលដែលមានតម្រូវការប្រើប្រាស់ពេលមានភ្ញៀវទេសចរណ៍។ រថយន្តធុនតូច គឺសម្រាប់ដឹកក្រុមភ្ញៀវទេសចរណ៍ដែលមានចំនួនតិច ហើយនៅពេលដែលមានគេចង់ទិញ និយោជកលក់ និងទិញរថយន្តថ្មីជំនួស។
  - បើទោះជាកម្មករនិយោជិតផ្នែកជួសជុលរថយន្តបានលាឈប់ពីការងារអស់ នៅពេលដែលមានរថយន្តខូច និយោជកអាចយករថយន្តទៅជួសជុលនៅយានដ្ឋានផ្សេងទៀតបាន។
  - និយោជកមិនមានបំណងរំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់ទេ ហើយក៏មិនមានបំណងបិទក្រុមហ៊ុនដែរ។ ប៉ុន្តែ ប្រសិនបើនិយោជករំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិត និយោជកនឹងគោរពតាមច្បាប់ស្តីពីការងារ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជករំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៤នាក់ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចរំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៤នាក់ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត ដែរ ឬទេ?

មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ចែងថា៖ "*កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីនាក់ ឬច្រើននាក់ មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច*"។

មាត្រា ៦៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា៖ "*កិច្ចសន្យាការងារ គឺជាកិច្ចសន្យា ដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិតនិងនិយោជក។ កិច្ចសន្យានេះ ត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា*"។

យោងទៅតាមមាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៦៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបង្កើត ការកែប្រែ និងការរំលត់កាតព្វកិច្ចនៃកិច្ចសន្យាការងារត្រូវកើតឡើងចេញពីឆន្ទៈរបស់ភាគីនៃកិច្ចសន្យា គឺនិយោជក និងកម្មករនិយោជិត។ ដូចនេះ ភាគីដែលមានសិទ្ធិក្នុងការរំលាយកាតព្វកិច្ចនៃកិច្ចសន្យា គឺមានតែភាគីទាំងពីរនេះនៃកិច្ចសន្យាការងារតែប៉ុណ្ណោះ។ ភាគីម្ខាងនៃកិច្ចសន្យា មិនអាចបង្ខំភាគីម្ខាងទៀត ឱ្យធ្វើការរំលាយកាតព្វកិច្ចនៃកិច្ចសន្យា ដែលផ្ទុយពីឆន្ទៈរបស់ភាគីម្ខាងនោះឡើយ។ ( *សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣៤/១៣-ផាភីលៀន វេកស្តាយ ហេតុផលនៃសេច*

ARBITRATION COUNCIL

*ក្តីសម្រេច, លេខ ១៣៨/១៣-សួនឧស្សាហកម្ម មេនហាតធេន ហេតុផលនៃសេចក្តីសម្រេច, លេខ ០៣៩/១៤-អ៊ី ហ្គាមេន ខូ អិលធីឌី ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១, លេខ ៣០៨/១៤-ហ៊ុយ ចៀន (ខេមបូឌា) ខប ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣)*

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកមិនមានឆន្ទៈ ក្នុងការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទេ ដោយហេតុថា និយោជកត្រូវការកម្មករនិយោជិតដើម្បីដំណើរការរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនមានសិទ្ធិបង្ខំឱ្យនិយោជករំលាយកិច្ចសន្យាការងារ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិតចំនួន ១៤នាក់ ដោយផ្ទុយពីឆន្ទៈរបស់និយោជក ដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាឡើយ។ ក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ភាគីនៃកិច្ចសន្យាការងារអាចរំលាយកិច្ចសន្យាការងារតាមឆន្ទៈឯកឯងបាន ដោយហេតុផលសមរម្យ ឬកំហុសធ្ងន់។ ប៉ុន្តែ បើភាគីណាមួយគ្មានឆន្ទៈក្នុងការរំលាយកិច្ចសន្យាការងារ មិនមានច្បាប់ណាតម្រូវឱ្យភាគីនោះត្រូវតែរំលាយកិច្ចសន្យាការងារតាមការចង់បានរបស់ភាគីម្ខាងទៀតឡើយ។ ហេតុនេះ ភាគីនិយោជកមិនមានកាតព្វកិច្ចត្រូវរំលាយកច្ចិសន្យាការងារ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ តាមការទាមទាររបស់កម្មករនិយោជិតទេ។ លើសពីនេះ នៅក្នុងសវនាការ កម្មករនិយោជិតបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចនូវរូបមន្តគណនាប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចពិចារណាតាមការស្នើសុំនេះបានទេ ដោយហេតុថា និយោជកមិនទាន់រំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិត។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជករំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៤នាក់ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជករំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៤នាក់ និងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**
ឈ្មោះ ៖ **អ៊ុង សុទ្ធី**
ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទួន ស៊ីផាន់**

ហត្ថលេខា ៖-------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ិនឈា**

ហត្ថលេខា ៖ -------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL